# ហោជាងក្នុងស្ថាបត្យកម្មខ្មែរសម័យបុរាណ (មុនសម័យអង្គរ-សម័យអង្គរ)"

ក្នុងប្រវត្តិសាស្ត្រនៃតំបន់អាស៊ីអាគ្នេយ៍ គេដឹងយ៉ាងច្បាស់ថា ខ្មែរ គឺជារដ្ឋមួយក្នុងចំណោមរដ្ឋទាំងបួន (ខ្មែរ ចាម មន ជ្វា) ដែលទទួលឥទ្ធិពលអារ្យធម៌ឥណ្ឌាយ៉ាងជ្រាលជ្រៅ ចាប់តាំងពីរវាងដើមគ្រិស្តសករាជមក ពោល ទាំងផ្នែកសាសនា ភាសា អក្សរសាស្ត្រ ច្បាប់ និងទស្សនិវជ្ជា។ ទោះជាយ៉ាងណាក៏ដោយ ក្នុងវិស័យស្ថាបត្យកម្មប្រាសាទបុរាណ សិល្បករខ្មែរមិនបានចម្លងតាមគំរូស្ថាបត្យកម្មឥណ្ឌាទាំងស្រុងនោះទេ។ ផ្ទុយទៅវិញ បុព្វបុរសខ្មែរបានច្នៃប្រតិដ្ឋទៅលើឥទ្ធិពលទាំងនោះជាមួយសិល្បៈផ្ទាល់ខ្លួន រហូតបង្កើតបានជាអត្តសញ្ញាណមួយរបស់ខ្លួន ដែលមានភាពខុសប្លែកពីសំណង់នៅឥណ្ឌាយ៉ាងច្បាស់ក្រឡែត។ ក្នុងចំណោមគ្រឿងបង្គុំស្ថាបត្យកម្មដែលឆ្លុះបញ្ចាំងអំពីភាពខុសប្លែក និងភាពខ្ពង់ខ្ពស់នៃសិល្បៈខ្មែរនេះ "ហោជាង" គឺជាផ្នែកដ៏លេចធ្លោបំផុតមួយដែលគួរឱ្យកត់សម្គាល់។ តើហោជាងក្នុងស្ថាបត្យកម្មខ្មែរមានអត្ថន័យ និងតួនាទីដូចម្តេចខ្លះ?

កន្លងមក មានអ្នកស្រាវជ្រាវប្រវត្តិសិល្បៈជាច្រើន បានឱ្យនិយមន័យហោជាងដូចគ្នាខ្លះ និងខុសគ្នាខ្លះ។ ជាក់ស្តែង លោក Henri Marchal បានឱ្យនិយមន័យហោជាង (Fronton) ថា គឺជាផ្នែកដាច់ដោយឡែកមួយដែលមានទីតាំងស្ថិតនៅខាងលើផ្តែរទ្វារ ដែលគេប្រើប្រាស់សម្រាប់បិទបាំងគ្រឿងបង្គុំដំបូល និងប្រើប្រាស់សម្រាប់តុបតែងនៅតាមថ្នាក់នៃដំបូលប្រាសាទ ហើយជាចំណុចដែលសិល្បករខ្មែរប្រើដើម្បីសម្រាលទម្ងន់ថ្មភក់ ឱ្យទៅជាភាពទន់ភ្លន់តាមរយៈក្បាច់ភ្ញីវល្លិ និងរូបចម្លាក់ដែលរស់រវើកបំផុត ពោល គឺជា "កន្លែងនៃសេរីភាពសិល្បៈ"។ ស្រដៀងគ្នានេះដែរ លោក Jean Boisselier កត់សម្គាល់តួនាទីរបស់ហោជាងនៅតាមប្រាសាទខ្មែរថា ហោជាងត្រូវតែស្ថិតនៅលើផ្តែរ ហើយបើផ្តែរជាគ្រឿងទ្រទ្រង់ទម្ងន់បញ្ឈរ នោះហោជាង គឺជាផ្ទៃដែលប្រើប្រាស់សម្រាប់តុបតែង និងនិទានរឿងទេវកថាសាសនាដើម្បីបង្គ្រប់សោភ័ណភាពនៃច្រកចូល។

ទោះបីជាយ៉ាងណានេះក្តី មានការបកស្រាយស្តីអំពីហោជាងដ៏គួរឱ្យចាប់អារម្មណ៍មួយរបស់លោក George Coedès នៅក្នុងស្នាដៃរបស់លោកក្នុងឆ្នាំ១៩៤៣ (បកប្រែជាភាសាអង់គ្លេសក្នុងឆ្នាំ១៩៦៣) ដែលមានចំណងជើងថា "*Angkor: An Introduction*" បានពន្យល់ថា ហោជាងនៅសម័យអង្គរដែលធ្វើឡើងជាស៊ុមរូបនាគ មិនមែនគ្រាន់តែជាគ្រឿងតុបតែងឡើយ ប៉ុន្តែវាជានិមិត្តរូបនៃ "ស្ពានឥន្ទធនូ" ព្រោះនៅក្នុងជំនឿខ្មែរ នាគ តំណាងឱ្យ "ទឹក" និង "ឥន្ទធនូ"។ តាមទស្សនៈ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

នេះ លោកយល់ថា នាគ គឺជាយានដើម្បីតភ្ជាប់ផែនដីទៅនឹងមេឃ។ ម្ល៉ោះហើយ ហោជាងដើរតួនាទីជា "ច្រកអន្តរកាល" ដែលអនុញ្ញាតឱ្យសត្វលោកចាកចេញពីពិភពមនុស្សឆ្លងកាត់ស្ពានឥន្ទធនូដើម្បីចូលទៅកាន់ទីស័ក្តសិទ្ធិ ឬភ្នំព្រះសុមេរុដែលជាទីគង់នៅរបស់ព្រះអាទិទេព។ ស្របគ្នាជាមួយទ្រឹស្តីនេះ លោក អាំង ជូលាន (២០០៧) បានពង្រីកទស្សនៈនេះឱ្យកាន់តែមានភាពស៊ីជម្រៅតាមបែបមនោគមវិជ្ជាខ្មែរ។ លោកបានចាត់ទុកហោជាងថាជាផ្នែកមួយនៃ **"សិរសា"** (ក្បាល) នៃសំណង់ ដែលជាកន្លែងផ្ទុកនូវសិរីសួស្តី និងជ័យមង្គល។ លោកកត់សម្គាល់ថា ហោជាង គឺជាទីលំនឹងនៃចក្រវាល បង្ហាញតាមរយៈចម្លាក់រឿងរ៉ាវទេវកថាផ្សេងៗ ដែលសុទ្ធសឹងឆ្លុះបញ្ចាំងអំពីសណ្តាប់ធ្នាប់នៃចក្រវាលទាំងមូល។

ទ្រឹស្តីខាងលើរបស់លោក អាំង ជូលាន ដែលយល់ថា ហោជាងប្រៀបបាននឹង "ក្បាល" គឺមានអត្ថន័យប្រហាក់ប្រហែលជាមួយឥណ្ឌាដែរ។ នៅឥណ្ឌាខាងជើង (សិល្បៈបែប Nagara) គេហៅហោជាងថា **"សុកនាស"** ដែលមានន័យត្រង់ថា "ច្រមុះសេក"។ វាជាផ្នែកដែលលយចេញពីតួប៉ម (Shikhara) នៅចំពីលើច្រកចូល មានរាងជាពាក់កណ្តាលរង្វង់ ឬរាងក្រចកសេះធំមួយ ដែលមើលទៅដូចជា "ច្រមុះ" របស់ប្រាសាទមែនទែន ហើយគេយល់ថា "សុកនាស" នេះ តំណាងឱ្យដង្ហើមរបស់ប្រាសាទ។ រីឯ នៅឥណ្ឌាខាងត្បូង (សិល្បៈបែប Dravida) គេនិយមលម្អក្បាច់មួយដែលហៅថា "គុឌុ" ពោល គឺអាចចាត់ទុកថាជាឫសគល់នៃហោជាង ប៉ុន្តែវាមិនមានទំហំធំស្កឹមស្កៃដូច "ហោជាង" នៃប្រាសាទខ្មែរទេ។ គុឌុ មានរាងជា "ក្រចកសេះ" តូចៗ ដែលគេឆ្លាក់នៅតាមជួរដំបូល ឬនៅតាមក្បាលសសរ ដែលមើលទៅហាក់ដូចជាបង្អួចបញ្ឆោតដែលមានរង្វង់មូលនៅចំកណ្តាល ហើយជារឿយៗមានចម្លាក់ "ព្រះភក្ត្រ" របស់មនុស្ស ឬទេពសម្លឹងមកក្រៅ។ នៅសិល្បៈឥណ្ឌាខាងត្បូង គេចាត់ទុក "គុឌុ" តំណាងឱ្យ "ភ្នែក" ឬ "បង្អួចពន្លឺ" "ភាពខ្ពង់ខ្ពស់" និងតំណាងឱ្យពួកទេពតូចៗ ឬសត្វសួគ៌ដែលមកចាំយាម និងសម្លឹងមើលការគោរពបូជារបស់មនុស្សលោក។

ត្រឡប់មកមើលអំពីសិល្បៈហោជាងរបស់ខ្មែរវិញ លោកស្រី Gilbert de Coral Rémusat បានចាត់ថ្នាក់ហោជាងខ្មែរចែកចេញជា ២ ទម្រង់ធំៗ រួមមាន ហោជាងរាងត្រីកោណ (Triangular) ដែលជាទម្រង់ដើមនិងសាមញ្ញ និងហោជាងរាងពហុជាន់ (Polylobed) ដែលមានរាងជារលក ឬរាងជងឆ្លូបត់បែនជាច្រើនជាន់។ នៅសម័យមុនអង្គរ (រចនាបថសំបូរព្រៃគុក) ហោជាងមិនទាន់មានទំហំស្កឹមស្កៃ ឬមានរាងពហុជាន់ដូចសម័យអង្គរឡើយ ពោល គឺភាគច្រើនគេឆ្លាក់ហោជាងនៅលើតដ្ឋប្រាសាទតែម្តង ដែលហោជាងទាំងនោះច្រើនមានរាងជា "ក្រចកសេះ" ឬ "រាងដូចជើងអក្សរ ក"។ ប៉ុន្តែ មកដល់រចនាបថព្រៃក្មេង និងកំពង់ព្រះ ហោជាងចាប់ផ្តើមវិវឌ្ឍបន្តិចម្តងៗពីរូប

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

រាងដូចក្រចកសេះ មកជារាង "ស្លឹកពោធិ៍" ឬ "រាងផ្ការ" ហើយមានការតុបតែងមានភាពទន់ភ្លន់ជាងមុន ប៉ុន្តែនៅរក្សាទម្រង់សាមញ្ញ និងមិនទាន់មានការឆ្លាក់រាយរ៉ាប់អំពីសាច់រឿងទេវកថាវែងឆ្ងាយនៅឡើយទេ។ ហោជាងនៅសម័យដំបូងៗទាំងនោះ មានរូបរាងស្ទើរតែដូចទៅនឹងហោជាង ឬក្បាច់គុឌុនៃសិល្បៈឥណ្ឌាខាងត្បូង គ្រាន់តែមានរូបរាងធំជាង និងខ្ពស់ត្រដែតជាងបន្តិច។ ចំណុចនេះស្តែងឱ្យឃើញថា ហោជាងខ្មែរនៅសម័យដំបូងៗ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសិល្បៈឥណ្ឌាខាងត្បូង (ឧទាហរណ៍ ដូចហោជាងនៅរូងភ្នំ Ajanta) ប៉ុន្តែ ខ្មែរបានច្នៃប្រតិដ្ឋមកជាសិល្បៈផ្ទាល់ខ្លួនប្រចាំតំបន់។ ដោយឡែក នៅសម័យអង្គរ ហោជាងខ្មែរមានរូបរាងធំស្កឹមស្កៃ និងមានលក្ខណៈបត់បែនជាច្រើនជាន់ (រាងទឹករលក) ដែលជួយបង្កើនសោភ័ណភាពដំបូលឱ្យមើលទៅកាន់តែខ្ពង់ខ្ពស់ និងអស្ចារ្យ។ លក្ខណៈពិសេសដាច់គេនៃហោជាងសម័យអង្គរនោះគឺ ការប្រើតួខ្លួននាគ ធ្វើជាស៊ុមព័ទ្ធជុំវិញហោជាង ដែលខាងចុងហោជាងបញ្ចប់ដោយ "**ក្បាលនាគ**" ឬ "**មករខ្លាក់នាគ**" ងើបឡើងយ៉ាងអង់អាច ពោល គឺមើលទៅជាការបោះជំហានដាច់ឆ្ងាយពីសិល្បៈឥណ្ឌា។ ហោជាងខ្មែរនៅសម័យអង្គរ សិល្បករបានយកឈុតឆាកល្បីៗនៃគម្ពីរនានា (ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា) ឆ្លាក់បង្ហាញជាសាច់រឿងយ៉ាងរស់រវើក ស្តែងឱ្យឃើញយ៉ាងច្បាស់អំពីតួនាទីសំណង់ប្រាសាទទាំងមូល គឺជាស្ថានរបស់ព្រះអាទិទេព។ ជាពិសេស គឺហោជាងនៅក្នុងរចនាបថបន្ទាយស្រី (គ.ស.៩៦៨-១០០០) មានរូបរាងជាកញ្ចុំដើងធ្មារ និងត្រីកោណត្រួតគ្នាចំនួនពីរជាន់ និងលម្អិតអំពីចម្លាក់ទេវកថាដ៏ឥតខ្ចោះ ដែលអ្នកស្រាវជ្រាវជាច្រើនឧបកិច្ចថាជា "**ត្បូងពេជ្រ ឬគ្រឿងអលង្ការនៃសិល្បៈខ្មែរ**"។ ចម្លាក់ហោជាងនៅសម័យអង្គរនេះហើយដែលបានពិភាក្សាខាងលើថា ជាហោជាងមានប្រើប្រាស់នាគព័ទ្ធជុំវិញហោជាង ជានិមិត្តរូបនៃស្ពានឥន្ទធនូដែលជាយានភ្ជាប់លោកិយទៅកាន់ស្ថានសួគ៌ ព្រោះហោជាងដើរតួនាទីជា "**ច្រកទ្វារសួគ៌**" ដែលត្រៀមទទួលអ្នកគោរពបូជាឱ្យចូលទៅកាន់ទីដ៏ស័ក្តិសិទ្ធិ។ ព្រមជាមួយគ្នានេះ ហោជាងសម័យអង្គរមានបន្ថែមនូវ "**ក្បាច់អណ្តាតភ្លើង**" នៅជុំវិញស៊ុមនាគ បញ្ជាក់អំពីតេជៈបារមី និងរស្មីដ៏ភ្លឺស្វាងនៃស្ថានទេព។ ហោជាងរាងពហុជាន់នេះ លោកស្រីបានសង្កត់ធ្ងន់ថា គឺជាការវិវឌ្ឍពីសាមញ្ញមកជាទម្រង់ដែលមើលទៅមានសោភ័ណភាពជារបៀបខ្មែរដាច់ដោយឡែកពីកាលដែលទទួលឥទ្ធិពលឥណ្ឌានៅសម័យដំបូងៗ។

ជារួមមក "ហោជាង" គឺជាសក្ខីភាពនៃភាពច្នៃប្រតិដ្ឋដ៏ខ្ពង់ខ្ពស់របស់បុព្វបុរសខ្មែរ ដែលបានប្រែក្លាយឥទ្ធិពលសិល្បៈឥណ្ឌាឱ្យទៅជាអត្តសញ្ញាណសិល្បៈខ្មែរដាច់ដោយឡែកមួយ។ ចាប់ផ្តើមពីទម្រង់ដូច "ក្រចកសេះ" សាមញ្ញនៅសម័យមុនអង្គរ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ជាមួយសិល្បៈឥណ្ឌាខាងត្បូង ហោជាងបានវិវឌ្ឍខ្លួនជាលំដាប់រហូតដល់សម័យអង្គរ ដែលមានរូបរាងធំស្កឹមស្កៃ និងមានរចនាសម្ព័ន្ធនាគព័ទ្ធជុំវិញ។ ហោជាងមិនត្រឹមតែដើរតួនាទីជាគ្រឿងបិទបាំងគ្រឿងបង្គុំដំបូល ឬជាទីលំហនៃសេរីភាពសិល្បៈសម្រាប់សិល្បករខ្មែរប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជា "ច្រកអន្តរកាល" ឬ "ច្រកទ្វារចូល" ជានិម្មិតរូបនៃស្ពានឥន្ទនូដែលភ្ជាប់លោកិយឆ្ពោះទៅកាន់ស្ថានសួគ៌។ យោងតាមរយៈចម្លាក់រឿងរ៉ាវទេវកថាដ៏រស់រវើក ហោជាងបានក្លាយជាចំណុចកណ្ដាលនៃលំនឹងចក្រវាល និងជាគ្រឿងលម្អដែលបញ្ជាក់ពីតេជៈបារមីនៃស្ថានទេព។ សរុបមក ហោជាងគឺជាគ្រឿងបង្គុំស្ថាបត្យកម្មដ៏សំខាន់ដែលមិនអាចខ្វះបាន ក្នុងការកំណត់និយមន័យនៃសោភ័ណភាព និងមនោគមវិជ្ជាសាសនានៅតាមប្រាសាទខ្មែរបុរាណ។

## បញ្ជីឯកសារពិគ្រោះ


Ang, C. (2007) *Brahmāṇḍa*: The Universe. Phnom Penh: Yosothor.

Bénisti, M. (2003) *Stylistics of Early Khmer Art*. New Delhi: Indira Gandhi National Centre for the Arts.

Boisselier, J. (1966) *Le Cambodge: Manuel d'archéologie d'Extrême-Orient*. Paris: Picard.

Brown, P. (1959) *Indian Architecture (Buddhist and Hindu Periods)*. 4th edn. Bombay: D.B. Taraporevala Sons.

Coedès, G. (1963) *Angkor: An Introduction*. Translated by E.F. Gardiner. Hong Kong: Oxford University Press.

Coomaraswamy, A.K. (1927) *History of Indian and Indonesian Art*. London: Edward Goldston.

Coral Rémusat, G. de. (1940) *L'art khmer: Les étapes de son évolution*. Paris: Les Éditions d'Art et d'Histoire.

Giteau, M. (1975) *Iconographie du Cambodge d'après les bas-reliefs*. Paris: École Française d'Extrême-Orient.

Kramrisch, S. (1946) *The Hindu Temple*. Calcutta: University of Calcutta.

Mannikka, E. (1996) *Angkor Wat: Time, Space, and Kingship*. Honolulu: University of Hawai'i Press.

Marchal, H. (1951) *Le décor khmer*. Paris: Van Oest.

Stern, P. (1927) *Le Bayon d'Angkor et l'évolution de l'art khmer*. Paris: Paul Geuthner.


អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ហោជាងប្រាសាទភ្នំឈ្ងោក ខេត្តកំពត (ចុងស.វ.ទី៦ ឬដើមស.វ.ទី៧)



រូបលេខ២៖ ហោជាងប្រាសាទសណ្ដាន់ សំបូរព្រៃគុក (ស.វ.ទី៧)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ហោជាងប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង (ដើមស.វ.ទី៨)



រូបលេខ៤៖ ហោជាងប្រាសាទភ្នំបូក ខេត្តសៀមរាប (ចុងស.វ.ទី៩)



រូបលេខ៥៖ ហោជាងប្រាសាទក្រចាប់ តំបន់ប្រាសាទកោះកេរ (ពាក់កណ្តាល ស.វ.ទី១០)



រូបលេខ៦៖ ហោជាងប្រាសាទបន្ទាយស្រី ខេត្តសៀមរាប (ចុងស.វ.ទី១០)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧ៈ ហោជាងប្រាសាទបន្ទាយស្រី ខេត្តសៀមរាប (ចុងស.វ.ទី១០)



រូបលេខ៨ៈ ហោជាងប្រាសាទបន្ទាយស្រី ខេត្តសៀមរាប (ចុងស.វ.ទី១០)



រូបលេខ៩៖ ហោជាងប្រាសាទភ្នំជីសូរ ខេត្តតាកែវ (ស.វ.ទី១១)



រូបលេខ១០៖ ហោជាងប្រាសាទស្នែងក្របីខាងជើង ខេត្តព្រះវិហារ (ស.វ.ទី១១)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ ហោជាងប្រាសាទព្រះខ័ន ខេត្តសៀមរាប (ចុងស.វ.ទី១២ ដើមស.វ.ទី១៣)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION